# ១. ឆ្នាំមុន chnammun

១) ឆ្នាំមុនបងបានជួបនឹងអូនម្ដង ច្រើនខែកន្លង បងខានបានជួបស្រីពៅ ទឹកភ្នែកសោកា រំពឹងឯណាឥឡូវ បងចាំមើលផ្លូវ បាត់សូន្យដូចពាក្យសន្យា

chnammun baaŋ baan cuəp nɨŋ ?oun mdaaŋ (mnaaŋ) craən khae kanlaaŋ baaŋ khaan baan cuəp srəy pɨw tɨk phnaek saokaa rumpɨŋ ?aenaa ?əyləw baaŋ cam məəl phləw bat soun douc peˇə? sanyaa

២) ឆ្នាំមុន បងបានជួបនឹងអូនស្រី ពាក្យពេចន៍សម្ដី មានន័យក៏ សែនពិរោះ តែក្នុងពេលនេះ ហេតុអ្វីក៏ស្រីប្រែផ្លាស់ ភ្លេចស្នេហ៍យើងចាស់ បាត់សូន្យភ្លេចទាំងសម្ដី

chnammun baaŋ baan cuəp nɨŋ ?oun srəy peˇə? pec samdəy miən nɨy kaa saen piiruˇəh tae knoŋ peel nih haet ?wəy kaa srəy prae phlaah (plaah) phlɨc snae yəəŋ cah bat soun phlɨc teˇəŋ samdəy

៣) យប់អើយយប់យន់ បងគន់មើលតែផ្លូវស្រី ក្នុងប្រាំពីររាត្រី បងសែនអាល័យស្នេហា យប់អើយយប់ស្ងាត់បាត់សង្ស័រ ឱ្យខ្ញុំរំពឹងនរណាបើចន្ទ្រថ្លាឃ្លាតឆ្ងាយ

yup ?aəy yup yoˇən baaŋ koˇən məəl tae phləw srəy knoŋ pram pii riətrəy baaŋ saen ?aalay snaehaa yup ?aəy yup sŋat bat saŋsaa ?aoy khɲom rumpɨŋ nɔra?naa baə can thlaa khliət chŋaay

៤) អូនអើយ បងមិនអាចភ្លេចបានទេ ឆោមកែវមាសមេ បងសែន ស្នេហាពេកក្រៃ រំពឹងថាជួបរាល់ពេលនឹងរាល់រាត្រី បងសែន(នឹក)អាល័យ ស្រីថ្លៃពុំមានពេលភ្លេច

?oun ?aəy baaŋ mɨn ?aac phlɨc baan tee chaom kaew miəh mee baaŋ saen snaehaa peek kray rumpɨŋ thaa cuep roˇəl peel nɨŋ roˇəl riətrəy baaŋ saen[nɨk] ?aalay srəy thlay pum miən peel plɨc ៣) , ៤)

# សព្វ

១)  មុន បង  បាន ជួប នឹង អូន ខែ ខាន ពៅ ទឹក សោកា រំពឹង ចាំ  មើល បាត់ សូន្យ ដូច ពាក្យ  ពេចន៍ មាន ន័យ ក៏ សែន ពីរោះ តែ ពេល នេះ ហេតុ ក៏  យើង ចាស់ សូន្យ  ទាំង សម្ដី យប់  អើយ  យប់  យន់  គន់  តែ  សែន  រំពឹង នរណា បើ មិន អាច ទេ  ឆោមកែវ មាសមេ ថា រាល់ ពេល នឹង រាត្រី  នឹក អាល័យ  ពុំ ពីរ

២) ឆ្នាំ  ម្ដង ច្រើន ស្រី  ក្អែក  ផ្លូវ ក្នុង អ្វី  ប្រែ  ផ្លាស់  ក្មេច ស្នេហ៍  ក្នុង ប្រាំ រាត្រី ស្នេហា  ស្ងាត់  ខ្ញុំ  ថ្លា  ឃ្លាត ឆ្ងាយ ក្មេច ពេកក្រៃ ថ្ងៃ

៣)   កន្លង សន្យា សម្ដី សង្សារ

៤)  ឯណា ឥឡូវ ឱ្យ ចន្ទ្រ

# ២. សារិកាកែវអើយ saarikaakaəw ?aəy

១) សារិកាកែវអើយស៊ីអីកងៗ សារិកាកែវអើយស៊ីអីកងៗ

ស៊ីផ្លែដំបង ប្រចឹកគ្នាលេង អើយសាវៗឡេ!

ស្លាប់វាចាក់ក្បាច់ មាត់វាធ្វើភ្លេង ស្លាប់វាចាក់ក្បាច់ មាត់វាធ្វើភ្លេង

ប្រចឹកគ្នាលេង លើមែកប្រីក្សា អើយសាវៗ ឡេ!

saarikaakaəw ?aəy sii ?əy kaaɳ kaaɳ

saarikaa kaəw ?aəy sii ?əykaaɳ kaaɳ

sii phlae dambaɳ prɑcək kniə leeɳ ?aəy saaw saaw lei

slaap wiə ca? kbac moˇət wiə thwəə pleeɳ slaap wiə ca? kbaac moˇət wiə thwəə pleeɳ

prɑcək khniə leeɳ ləə maek prɨksaa ?aəy saaw saaw lei

២) កញ្ចាញ់ចេកអើយ លោតទំបុងគគីរ កញ្ចាញ់ចេកអើយ

លោតទំបុងគគីរ មេម៉ាយកូនពីរ ឆ្ងុយដូចដូងដុត អើយសាវៗ ឡេ!

kɑɲcaɲceik ?aəy loot tum coɳ kɔɔkii

kɑɲcaɲceik ?aəy loot tum coɳ kɔɔkii

mee maay koun pii chɳoy douc douɳ dot ?aəy saaw saaw lei

៣) កញ្ចាញ់ចេកអើយ លោតព័ទ្ធមាត់បឹង កញ្ចាញ់ចេកអើយ លោតព័ទ្ធមាត់បឹង

ស្រីណាប៉ិនខឹង ស្រីអ្នឹងថ្នមប្តី អើយសាវៗ ឡេ!

kɑɲcaɲceik ?aəy loot puˇət moˇət bəɳ kɑɲcaɲceik ?aəy loot puˇət moˇət bəɳ

srəy naa pən khəɳ srəy nɨɳ ceh thnɑm pdəy ?aəy saaw saaw lei

៤) កញ្ចាញ់ចេកអើយ លោតទំចុងឫស្សី     កញ្ចាញ់ចេកអើយ លោតទំចុងឫស្សី

ចុះខឹងអី ចង់ក្បិនទល់ព្រឹក អើយសាវៗ ឡេ!

kaɲcaɲceik ?aəy loot tum caɳ rɨssəy     kaɲcaɲceik ?aəy loot tum caɳ rɨssəy

coh khəɳ ?əy caɳ kbən tuˇəl prɨk ?aəy saaw saaw lei

៥) ឬមួយស្អប់បង ជាអ្នកប្រមឹក     ឬមួយស្អប់បង ជាអ្នកប្រមឹក

ឬមួយស្រីនឹក ដល់សង្សារចាស់ អើយសាវៗ ឡេ!

rɨɨ muəy s?ap baaɳ ciə neˇəh praamɨk  rɨɨ muəy s?ap baaɳ ciə neˇəh praamɨk

rɨɨ muəy srəy nɨk dal saɳsaa cah ?aəy saaw saaw lei

១) (ម្តងទៀត)

៦) កញ្ចាញ់ចេកអើយ លោតទំចុងក្តាត កញ្ចាញ់ចេកអើយ  លោតទំចុងក្តាត

ឃើញស្រីស្អាតៗ លែងចង់ចូលបួស អើយសាវ ៗឡេ!

kaɲcaɲceik ?aəy loot tum caɳ kdaad     kaɲcaɲceik ?aəy loot tum caɳ kdaad

kəəɲ srəy s?aat s?aat lɛɛɲ caɳ coul buəh ?aəy saaw saaw lei

៧) បើបានជាគូ ស៊ូលេបខ្សាច់ក្រួស បើបានជាគូ ស៊ូលេបខ្សាច់ក្រួស

លែងគិតរៀងបួស ឱ្យតែបានអូន អើយសាវៗ ឡេ!

baə baan ciə kuu suu leep khsac kruəh  baə baan ciə kuu suu leep khsac kruəh

lɛɛɳ kɨt rɨəɳ buəh ?aoy tae baan ?oun ?aəy saaw saaw lei

៨) កញ្ចាញ់ចេកអើយ លោតទំចុងត្រកួន កញ្ចាញ់ចេកអើយ
លោតទំចុងត្រកួន ឱ្យតែបានស្ងួន ធ្វើអីក៏ធ្វើដែរ អើយសាវៗ ឡេ!

kaɲcaɲceik ?aəy loot tum caɳ trakuən    kaɲcaɲceik ?aəy loot tum caɳ trakuən

?aoy tae baan sɳuən  thwəə ?əy kaa thwəə dae ?aəy saaw saaw lei

៩) កញ្ចាញ់ចេកអើយ លោតជាន់ផើងតាប៉ែ កញ្ចាញ់អេចអើយ
លោតជាន់ផើងតាប៉ែ ក្រមុំសៅកែ ជួរអែមៗ អើយសាវៗ ឡេ!

kaɲcaɲceik ?aəy loot coˇən phəəɳ taa pae

kaɲcaɲceik ?aəy loot coˇən phəəɳ taa pae

kramom sawkae cuu?aem cuu?aem    ?aəy saaw saaw lei

## ៣. ចង់បានប្រពន្ធខ្មែរ caɲ baan prapoˇən khmae

១) អេ...ចង់បាននាងអើយប្រពន្ធមួយ នាងអើយចង់បាននាងអើយប្រពន្ធមួយ ចង់បាននាងអើយប្រពន្ធមួយ នាងអើយចង់បាននាងអើយប្រពន្ធមួយ បើបាននាងអើយបងលែងព្រួយ បើបាននាងអើយបងលែងព្រួយ ព្រោះបងបានភួយៗសាច់

?ee....caɲ baan niəɲ ?aəy prapoˇən muəy niəɲ ?aəy caɲ baan niəɲ ?aəy prapoˇən muəy caɲ baan niəɲ ?aəy prapoˇən muəy niəɲ ?aəy caɲ baan niəɲ ?aəy prapoˇən muəy baə baan niəɲ ?aəy baaɲ lɛɛɲ pruəy baə baan niəɲ ?aəy baaɲ lɛɛɲ pruəy pruˇəh baaɲ baan phuəy phuəy sac

២) ចង់បាននាងអើយប្រពន្ធមួយ នាងអើយចង់បាននាងអើយប្រពន្ធមួយ ចង់បាននាងអើយប្រពន្ធមួយ ចង់បានប្រពន្ធមួយគឺប្រពន្ធខ្មែរ សាសគេបងមិនយកទេ សាសគេបងមិនយកទេ ព្រោះបងជាខ្មែរពូជអង្គរ

caɲ baan niəɲ ?aəy prapoˇən muəy niəɲ ?aəy caɲ baan niəɲ ?aəy prapoˇən muəy caɲ baan niəɲ ?aəy prapoˇən muəy caɲ baan prapoˇən muəy kɨɨ prapoˇən khmae saah kee baaɲ mɨn yɔɔk tee saah kee baaɲ mɨn yɔɔk tee pruˇəh baaɲ ciə khmae puuc ?aɲkɔɔ

៣) អេ...អង្គុយគិតនាងអើយបើមានប្រាក់ បងយកប្រពន្ធម្នាក់នាងអើយឱ្យមកមើល អង្គុយគិតនាងអើយបើមានប្រាក់បងយកប្រពន្ធម្នាក់នាងអើយឱ្យមកមើល ការងារបងមិនឱ្យធ្វើ ការងារបងមិនឱ្យធ្វើ ឱ្យដេកចាំមើលតែហ្នឹងប្រាក់

?ee.... ?aɲkuy kɨt niəɲ ?aəy baə miən pra? baaɲ yɔɔk prapoˇən mneˇəh niəɲ ?aəy ?aoy mɔɔk məəl ?aɲkuy kɨt niəɲ ?aəy baə miən pra? baaɲ yɔɔk prapoˇən mneˇəh niəɲ ?aəy ?

aoy mɔɔk məəl  kaa ɳiə baaɳ mɨn ?aoy thwəə kaa ɳiə baaɳ mɨn ?aoy thwəə  ?aoy deik cam məəl tae nəɳ pra?

៤) ចង់បាននាងអើយប្រពន្ធមួយ ចង់បានប្រពន្ធមួយពិបាកដល់ម្ទឹង ចង់បាននាងអើយប្រពន្ធមួយ ចង់បានប្រពន្ធមួយពិបាកដល់ម្ទឹង បើប្រាក់ក៏គ្មានមួយដម្លឹង បើប្រាក់ក៏គ្មានមួយដម្លឹង នឹងឱ្យប្រឹងធ្វើចុះយ៉ាងណា

cɑɳ baan niəɳ ?aəy prɑpoˇən muəy cɑɳ baan prɑpoˇən muəy pibaak dɑl mlɨɳ cɑɳ baan niəɳ ?aəy prɑpoˇən muəy cɑɳ baan prɑpoˇən muəy pibaak dɑl mlɨɳ baə pra? kɑɑ kmiən muəy dɑmləɳ baə pra? kɑɑ kmiən muəy dɑmləɳ  nɨɳ ?aoy prəɳ thwəə coh yaaɳ naa

៥) អេ...ចង់បាននាងអើយប្រពន្ធមួយ ចង់បានប្រពន្ធគិតព្រួយយ៉ាងខ្លាំង ចង់បាននាងអើយប្រពន្ធមួយ ចង់បានប្រពន្ធគិតព្រួយយ៉ាងខ្លាំង បើសិនឱ្យយកប្រពន្ធបារាំង បើសិនឱ្យយកប្រពន្ធបារាំង មាឌធំសចាំងក៏មិនយកដែរ

?ee...cɑɳ baan niəɳ ?aəy prɑpoˇən muəy cɑɳ baan prɑpoˇən muəy kɨt pruəy yaaɳ khlɑɳ cɑɳ baan niəɳ ?aəy prɑpoˇən muəy cɑɳ baan prɑpoˇən muəy kɨt pruəy yaaɳ khlɑɳ  baə sən ?aoy yɔɔk  prɑpoˇən baaraaɳ baə sən ?aoy yɔɔk  prɑpoˇən baaraaɳ miət thom sɑɑ cɑɳ kɑɑ mɨn yɔɔk dae

៦) ចង់បាននាងអើយប្រពន្ធខ្មែរ ចង់បានប្រពន្ធខ្មែរស្តាប់ឱពាក្យប្តី ចង់បាននាងអើយប្រពន្ធខ្មែរ ចង់បានប្រពន្ធខ្មែរស្តាប់ឱពាក្យប្តី គោរពនាងអើយប្រពៃណី គោរពនាងអើយប្រពៃណី ដែលចារតាំងពីបុរាណ (២ ដង)

cɑɳ baan niəɳ ?aəy prɑpoˇən khmae cɑɳ baan  prɑpoˇən khmae sdap
?ao peˇə? pdəy   cɑɳ baan niəɳ ?aəy prɑpoˇən khmae cɑɳ baan  prɑpoˇən khmae sdap
?ao peˇə? pdəy  koorop niəɳ ?aəy prɑpɨynii koorop niəɳ
?aəy prɑpɨynii dael caa taɳ pii booraan (២ ដង)

# ៤. ចំប៉ាបាត់ដំបង campaa batdambaaɳ

១) ឱ!បាត់ដំបងបណ្ដូលចិត្តអើយ ខ្ញុំសូមលាហើយ លាទាំងអាល័យ តាំងពីរូបខ្ញុំបាន ឃ្លាតទៅឆ្ងាយ ខ្វល់ខ្វាយនឹកស្ដាយ ពុំមានពេលល្ហែ ។

?ao batdambaaɳ bandoul cət ?aey khɲom soum liə haəy liə tiəɳ ?aalay

taɳ pii ruup khɲom baan kliət tɨw chɲaay khwalkhwaay nɨk sdaay pum miən peel lhae

២) ឱ!បាត់ដំបងកង់កម្មវាសនា ដែលខ្ញុំប្រាថ្នា គ្មានពេលទំនេរ បើសិនជាគូ ខ្ញុំពីបុព្វេ សូមឱ្យមាសស្នេហ៍ នឹកឃើញគ្រាដើម ។

(បន្ទរ) កន្លងយូរឆ្នាំចាំទេស្ងួន មានតែរូបអូនដែលជាដង្ហើម ចំពោះនួនល្អងចិត្តបងសង្ឃឹម សង្ឃឹម ញញឹមថាបានជាគូវាសនា ។

?ao batdambaaɳ kaɳ kam wiəhsnaa dael khɲom pratthna kmiən peel tumnee baə sən ciə kuu khɲom pii buppee soum ?aoy miəh snae nɨk dal kriə daəm

(chorus) kanlaaɳ yuu chnam cam tee sɲuən miən tae ruup ?oun dael ciə daaɳhaəm campuˇəh nuən l?aaɳ cət baaɳ saɳkɨm saɳkɨm ɲɔɔɲɨm thaa baan ciə kuu wiəhsnaa

៣) ឱ! បាត់ដំបង ខ្ញុំប៉ងយូរហើយ តើថ្ងៃណាឡើយ បានយល់កត្រ្កា ចិតជ្រួលច្របល់ រាល់ថ្ងៃខ្លោចផ្សារ ចង់បានចំប៉ាបាត់ដំបងអើយ ។

?ao batdambaaɳ khɲom paaɳ yuu haəy taə thɲay naa laəy baan yuəl peˇə?traa cət cruəl craabal roˇəl thnaay khlaoc phsaa caɳ baan campaa batdambaaɳ ?aəy

៤) (បញ្ចប់) ចង់បានចំប៉ាបាត់ដំបងអើយ...

caɳ baan campaa batdambaaɳ ?aəy

# ៥. សារ៉ាវ៉ាន់ស្លៀកខ្យល់ដណ្ដប់មេឃ

saaraawaan  sliək khyɑl dɑndɑp meek

១) អូ អូ អូយ សូមអញ្ជើញអេហ៊ើ រាំលេង ចូលមកចុះ ប្រុសស្រីចាស់ឬក្មេង មករាំលេងសារ៉ាវ៉ាន់ ឥតប្រកាន់ ឋានះឡើយ

?ou ?ou ?ouy soum ?ɑɲcəəɲ ?ei ?ei roˇəm leeɳ coul mɔɔk coh

proh srəy cah rɨɨ kmeiɳ mɔɔk roˇəm leeɳ saaraawaan ?ət prɑɑkan thaana laəy

២) ស្លៀកខ្យល់សារ៉ាវ៉ាន់ស្លៀកខ្យល់ ស្លៀកខ្យល់សារ៉ាវ៉ាន់ស្លៀកខ្យល់ដណ្ដប់មេឃ សារ៉ាវ៉ាន់ អើយ អេណា មកស្លៀកខ្យល់មកដណ្ដប់មេឃ អេណា

sliək khyɑl saaraawan sliək khyɑl sliək khyɑl saaraawan sliək khyɑl dɑndɑp meek

saaraawan ?aəy ?ei naa mɔɔk sliək khyɑl mɔɔk dɑndɑp meek ?ei naa

៣) ក្រុមនេះទើបនិងបើកថ្មី ជនប្រុសស្រីរង់ចាំយូរលង់ រៀបចំល្អត្រចង់ រាំវង់ រាំវង់ សារ៉ាវ៉ាន់ សារ៉ាវ៉ាន់បង់បោយ បង់បោយបង់បោយសារ៉ាវ៉ាន់ រាំបង់បោយសារ៉ាវ៉ាន់អើយ អេណា (២)

krom nih təəp nɨɳ baək thməy coˇən proh srəy roˇəɳ cɑm yuu loˇəɳ riəp cɑm l?ɑɑ trɑɑcɑɳ

roˇəm woˇəɳ roˇəm woˇəɳ saaraawan  saaraawan bɑɳbaoy bɑɳbaoy  bɑɳbaoy sarawan

roˇəm bɑɳbaoy saaraawan ?aəy ?ei naa  (២)

៤) ក្រុមនេះល្បីឈ្មោះសំខាន់ មកកំសាន្ត បានអាយុវែង សូមអញ្ជើញចាស់ឬក្មេង រាំលេង រាំលេងសារ៉ាវ៉ាន់ សារ៉ាវ៉ាន់ទៅមុខ ទៅមុខ ទៅមុខ សារ៉ាវ៉ាន់
រាំទៅមុខសារ៉ាវ៉ាន់អើយ អេណា (២)

krom nih lbəy chmuˇəh sɑmkhan mɔɔk kɑmsaan baan ?aayu wɛɛŋ soum ?ɑɲcəəɲ cah rɨɨ kmeiŋ roˇəm ləəŋ roˇəm ləəŋ saaraawan saaraawan tɨw muk tɨw muk tɨw muk saaraawan roˇəm tɨw muk saaraawan ?aəy ?einaa (២)

៥) មកស្រូបយកខ្យល់អាកាស មេឃស្រឡះ អប់ក្លិនបុប្ផា ស្រីស្អាតដូចទេវតា ត្រៀបត្រាចាំរាំ សារ៉ាវ៉ាន់ សារ៉ាវ៉ានថយក្រោយ ថយក្រោយ ថយក្រោយសារ៉ាវ៉ាន់ រាំថយក្រោយសារ៉ាវ៉ាន
អើយ អេណា

mɔɔk sroup yɔɔk khyɑl ?aakaah meek srɑɑlah ?ɑp klən bopphaa srəy s?aat douc teeveˇədaa triəptraa cam roˇəm saaraawan saaraawan thɑykraoy thɑykraoy thɑykraoy saaraawan roˇəm thɑykraoy saaraawan ?aey ?einaa

# ៦. ម្អមស្រែ m?ɑɑm srae

១ ) ភ្លៀងធ្លាក់ដើមឆ្នាំ ស្រោចជោកជាំវាលស្រែ កង្កែបក្អាតយំ អែៗ ធម្មជាតិប្រែពណ៌ស្រស់ថ្លា ត្រួយម្អមលាស់ថ្មី ឃើញស្រែនឹកស្រីជីវា ស្នាមស្នេហ៍ក្រោមដួងចន្ទ្រា ក្លិនជាប់នាសា ម្អមស្រែដួងចិត្ត

phliəɳ thleˇə? daəm chnam sraoc cook coˇəm wiəl srae kɑɳkaep k?aat yum ?ae ?ae thoˇəmməciət prae puə srɑh thlaa truəy m?ɑɑm loˇəh thməy khəəɲ srae nɨk srəy ciiwaa snaam snae kraom duəɳ cantriə klən coˇəp niəsaa m?ɑɑm srae duəɳ cət

២ ) ភ្លៀងធ្លាក់ដើមឆ្នាំ បងច្រៀងចាំខ្វើយៗ នឹកណាស់ម្អមស្រែបងអើយ ម្ដេចអូនចោលស្រែ ស្នេហ៍ស្និទ្ធ ដីថ្មីទីក្រុងធ្វីឱ្យអូនលង់ផ្លាស់ចិត្ត ភ្លេចស្រែធ្លាប់ស្មោះនៃបនិត្យ ដីធ្លាប់អាណិត ថ្នាក់ថ្នថ្នមស្នេហា

phliəɳ thleˇə? daəm chnam bɑɑɳ criəɳ cam khwaəy khwaəy nɨk naah m?ɑɑm srae bɑɑɳ ?aəy mdec ?oun caol srae snae snət dəy thməy tii kroɳ thwəə ?aoy ?oun luˇəɳ phlaah cət plec srae thloˇəp smɑh naepnɨt dəy thloˇəp ?aanət thna? thnɑɑm snaehaa

៣ ) ឱ បេះដូងអើយ បៀមជាប់តែទុក្ខ ចិត្តខ្វល់មិនសុខ នៅនឹករឭក ម្អមស្រែបុប្ផា ធ្លាប់ដុះដីស្រែ ផ្លាស់ទៅទីក្រុង តើប្រែយ៉ាងណា ខ្លាចផុងលង់ខក អាត្មា បង្ខំឱ្យផ្ការីករោយរាយ

?ao beh douɳ ?aəy biəm coˇəp tae tuk cət khwɑl mɨn sok nɨw nɨk rɔlɨk m?ɑɑm srae bopphaa thloˇəp doh dəy srae phlaah tɨw tii kroɳ taə prae yaaɳ naa khlaac phoɳ loˇəɳ khɑɑk ?aattmaa baɳkham ?aoy phkaa riik rooyriəy

*៤ ) ភ្លៀងធ្លាក់ដើមឆ្នាំ រៀមច្រៀងផ្តាំតាមទឹក  សូមអ្នកជួយនាំចិត្តនឹក បណ្តាំដីស្រែស្រុកឆ្ងាយ ទោះម្អមខ្សោះក្លិន ត្រូវគេរំខានចិត្តកាយ  បងនៅទទួលមិនស្តាយ រង់ចាំចោមឆាយម្អមស្រែបង អើយ*

phliəɳ thleˇə? daəm chnam riəm criəɳ phdam taam tɨk soum neˇə? cuəy  noˇəm cət nɨk bandam dəy srae srok chɳaay  tuˇəh  m?aam khsah klən trəw kee rumkhaan cət kaay baaɳ nɨw tɔtuəl mɨn sdaay roˇəɳ cam chaom chaay  m?aam srae baaɳ ?aəy

៣ ) , ៤ )

# ៧. បេះដូងអូនសាងពីអ្វី beh douɳ ?oun saaɳ mɔɔk pii ?wəy

១) អូនមិនខ្មាសអៀនផ្លាស់ប្ដូរស្នេហ៍ ម្ដងស្ម័គ្រម្ដងទេឱ្យបងវង្វេង ឱ្យបងឈឺចាប់គ្មានពាក្យថ្លែងហួសនិយាយ អូនប្រាប់ឱ្យបងខំកាត់ចិត្ត បំភ្លេចស្នេហ៍ស្និទ្ធកុំនឹកស្ដាយ ហេតុអ្វីក៏អូន គិតថាងាយ ម្ល៉េះពិសី?

?oun mɨn khmah ?iən phlah phdou snae mdɑɳ smak mdɑɳ tee ?aoy bɑɑɳ woˇəɳweeɳ ?aoy bɑɑɳ chɨɨ cap khmiən peˇə? thlaeɳ huəh niyiəy ?oun prap ?aoy bɑɑɳ khɑm kat cət bɑmplec snae snət kom nɨk sdaay haet ?wəy kɑɑ ?oun kɨt thaa ŋiəy mleh pisəy

២) បើមិនស្មោះបងទេ ម្ដេចមាសមេ មកស្ម័គ្រធ្វើអ្វី ស្នេហ៍ហើយប្រែដោះដៃ លេបខ្ជាក់សម្ដីឥតអៀនខ្មាស់ បេះដូងអូនសាងមកពីអ្វី? ស្គាល់ពាក្យកក្ដី ទេស្ងួន សម្បកជាឈ្លួសចិត្តជាព្រានគ្មានមេត្តា ឈប់ស្ដាប់ឈប់ជឿ ឈប់ត្រូវការ មុខស្រស់ចិត្តល្វា ដូចមាសមេ ខ្លាចហើយរាងហើយរឿងស្នេហ៍អូនដឹងទេ ថាបងឈឺចាប់

baə mɨn smah bɑɑɳ tee mdec miəh mee mɔɔk smak thwəə ?wəy snae haəy prae dɑh day leep khceˇə? sɑmdəy ?ət ?iən khmah beh douɳ ?oun saaɳ mɔɔk pii ?wəy skoˇəl peˇə? pheˇə?kdəy tee sŋuən sɑmbɑɑk ciə chluuh cət ciə priən khmiən meettaa chup sdap chup ciə chup trəw kaa muk srɑh cət lwiə douc miəhmee khlaac haəy riəɳ haəy rɨəɳ snae ?oun dəɳ tee thaa bɑɑɳ chɨɨ cap

៣ ) ថ្ងៃលិចហើយរះសាជាថ្មី បំភ្លឺផែនដីឥតនឿយណាយ មិនអាចបំភ្លឺចិត្តបងឡើយ សែនអូអាប់ អូនក្បត់ស្នេហ៍បងឥតអាសូរ ដូចទឹកដែលហូរឥតត្រលប់ បេះដូងរបួសសែនចុកចាប់ ស្មើរក្សិនក្ស័យ

thɳay lɨc haəy reˇə saa ciə thməy bɑmphlɨɨ phaen dəy ?ət nɨəy naay mɨn ?aac bɑmphlɨɨ cət baɳ laəy saen ?ou?ap ?oun kbɑt snae bɑɑɳ ?ət ?aasou douc tɨk dael hou ?ət trɑɑlap beh douɳ rɔbuəh saen cok cap stəə ksən ksay

២ ) , ២ )

៤ ) អឺយ ថាបងឈឺចាប់ អឺ អឺ បេះដូងអូនសាងមកពីអ្វី ? (៥ ដង)

ឈឺចាប់ (៣ ដង) អឺ អឺ

?əəy thaa bɑɑɳ chɨɨ cap ?əy ?əə beh douɳ ?oun saaɳ mɔɔk pii ?wəy (5 times)

chɨɨ cap (3 times) ?əy ?əə

# ៨. ឈឺចាប់ផ្ទួនៗ chɨɨ cap  phtuən phtuən

១)  មិនសុំពេលវេឡាបងច្រើន រឿងដាក់ស្តែងមិនអាចបិទបាំង មិនរវល់បេះដូងជាប់គាំង ស្នេហ៍ភាន់ភាំងស្តាប់ទាំងចិត្តស្មោះ  សុំពេលត្រឹមមួយនាទី  ត្រឹមប៉ុននេះចុងក្រោយបង្អស់ ដាច់បម្រាមហាមស្នេហ៍ខ្លាចខុស  មិនឱ្យជ្រុលហួសខ្វះបងមិនបាន

mɨn som peel weeliə baaŋ craən rɨəŋ ceˇə? sdaeŋ mɨn ?aac bət baŋ mɨn rɔwuˇəl beh douŋ coˇəp khiəŋ snae phoˇən phiəŋ sdap tiəŋ cət smah som peel trəm muəy niətii trɨm pon nih coŋ kraoy baŋ?ah dac bamraam haam snae khlaac khoh  mɨn ?aoy crul huəh khwah baaŋ mɨn baan

២)  នៅពេលនេះត្រូវ call ទៅបង  ចង់ស្តាប់ពាក្យពិត  សម្របចិត្តមិនចង់បាំងបិទ នាំឈឺចាប់ មិនមែនជាបង  តើគេជាអ្នកណា  លើកទូរស័ព្ទវាចា បង្ខំឱ្យទឹកនេត្រាស្រក់  ត្រូវឈឺផ្ទួនៗ ហេតុអ្វី  តើស្រីបិតនៅត្រង់ណា ដឹងទេអូនឈឺផ្សារ ពេលគ្មានប្រុសជីវា  នៅក្បែរកាយ

nɨw peel nih trəw khaal tɨw baaŋ caŋ sdap peˇə? pɨt samraap cət mɨn  caŋ baŋ bət noˇəm chɨɨ cap mɨn mɛɛn ciə baaŋ taə kee  ciə neˇə? naa ləək turasap wiəcaa baŋkham ?aoy tɨk neetra sra?  trəw chɨɨ  phtuən phtuən haet ?wəy  taə srəy thət nɨw traŋ naa  dəŋ tee ?oun chɨɨ phsaa peel khmiən proh ciiwaa nɨw kbae kaay

៣ ) ហេតុអ្វីបងងាយប្រែចិត្ត ប្រែគំនិតបំភ្លេចថ្ងៃមុន បងសប្បាយអូនទុក្ខទូលភ្នំ សើចលាយយំមគ្នានអ្នកខ្វល់ខ្វាយ call មកអូនតែបន្តិច ជួយបន្ទប់លួងចិត្តនឹកស្តាយ លែងមានបងនែបនិនិត្យក្បែរកាយ បេះដូងនាងឈឺចាប់ទ្វេដង

haet ?wəy baaɳ ɳiəy prae cət prae kumnɨt bamplec thɳay mun baaɳ sapbaay ?ou tuk tuul phnum saəc liəy yum khmiən neˇə? khwalkhwaay khaal mɔɔk ?oun tae bantəc cuəy baanlap luəɳ cət nɨk sdaay lɛɛɳ miən baaɳ nɛɛp nɨt kbae kaay beh douɳ niəɳ chɨɨ cap twee daaɳ ២ ) , ២ )

# ៩.ទូរស័ព្ទនរណា tureˇəsap nɑɑranaa

១ ) តើអ្នកណាទៅ ទូរស័ព្ទមកមានការអ្វី  កណ្តាលរាត្រី  ឱ្យស្រីឈឺចាប់ម្ល៉េះណ៎ា ស្ទុះក្រោក
ងើបចេញគ្មានទោម្នេញផ្ដោះផ្ដងវាចា សារស័ព្ទជាមួយសង្សារ ទាំងកិរិយាបងនៅនឹងមុខ

taə neˇə? naa tɨw tureˇəsap mɔɔk miən kaa ?wəy  kɑndaal riətrəy ?aoy srəy chɨɨ cap mleh naa  stuh kraok ŋəəp ceiɲ khmiən too mneɲ phdɑh phdɑŋ wiəcaa saa sap ciə muəy sɑnsaa teˇəŋ pheˇəhriyiə bɑɑŋ  nɨw nɨŋ muk

២ )  ពាក្យផ្អែមល្ហែមនេះ ចាំច្បាស់បងប្រើពីមុនប្រើមុខប្រពន្ធ ពេលនេះឱ្យឈឺចាប់ចុក
បងសើចសប្បាយ ពេលសន្ទនា ពេញដោយក្ដីសុខ ឯអូនអង្គុយសំកុក ណែនដោយទុក្ខ ស្ដាប់
ពាក្យប្រុសថ្លៃ

peˇə? ph?aem lhaem nih cam cbah bɑɑŋ praə pii mun praə muk prɑɑpuˇən peel nih ?aoy chɨɨ cap cok bɑɑŋ saəc sɑpbaay peel sɑnteˇə?niə peeɲ daoy kdəy sok ?ae ?oun ?ɑŋkuy sɑmkok naen daoy tuk sdap peˇə? proh thlay

៣ )  សំឡេងទូរស័ព្ទ ឱ្យឈឺចាប់រៀងរាល់រាត្រី  ឈឺនឹងសំដី ដែលផ្អែមល្ហែមហួសប្រមាណ
គិតមានតែអូន បានពាក្យនេះពីប្រុសកល្យាណតែមិននឹកស្មាន ប្រុសកល្យាណបែកស្រីគ្រប់គ្នា

sɑmleeŋ tuureˇəsap ?aoy  chɨɨ cap riəŋ roˇəl riətrəy  chɨɨ nɨŋ sɑmdəy dael ph?aem lhaem huəh prɑɑmaan  kɨt miən tae ?aon baan peˇə? nih pii proh kɑlyaan tae mɨn nɨk smaan proh  kɑlyaan caek srəy krup khniə

៨ ) តើអ្នកណាទៅ ឱ្យបងងប់ងល់ដល់ម្លឹង ជួយប្រាប់ឱ្យដឹង កុំឱ្យអូននៅវេទនា បើបង ស្រឡាញ់អូនព្រមចេញមិននៅទាមទារ យកគេធ្វើជាភរិយា ឯរូបពុំងា សុំលាពីបង

taə neˇə? naa tɨw ?aoy bɑɑŋ ŋupŋuˇəl dɑl mləŋ cuəy prap ?aoy dəŋ kom ?aoy ?oun nɨw weeteˇəniə baə bɑɑŋ srɑlaɲ ?oun prɔɔm ceiɲ mɨn tɨw tiəm tiə yɔɔk kee thwəə ciə peˇə?riyiə ?ae ruup pum ŋiə som liə pii bɑɑŋ

# ១០.ស្ទូងស្រូវប្រវាស់ដៃ stuuɳ srae praawaah day

១ ) ប្រុស

អ្ហាអើយ អ្ហាអឺអឹងអើយ ភ្លៀងធ្លាក់មកផ្សិកផ្សក់
អូនអើយទឹកដក់ ពេញបាតត្រពាំង មេឃផ្គរ រន្ទះឆ្វេចឆ្វាច
លាន់ឮសូរណា ផូងផាំង ឮកង្កែបណា ហ៊ីងយំ
គីង្គក់ក៏ប្រើង ក្រតប្រណាំង ឮកង្កែបណា ហ៊ីងយំ
គីង្គក់ក៏ប្រើង ក្រតប្រណាំង ទ្រហឹងរំពង ក្នុងស្រែប្រាំង
អាខ្លះវាសាំង នៅលើគ្នា

?aa ?aəy ?aa ?əə ?əəɳ ?aəy phliəɳ thleˇə? mɔɔk phlək phlɑ?
?oun ?aəy tɨk dɑ? peeɲ baat traapeˇəɳ meek phkɔɔ roˇənteˇə chwəəcchwaac
loˇən lɨɨ sou nɑɑ phouɳphaaɳ lɨɨ kɑɳkaep nɑɑ hiiɳ yum
kiiɳkoˇə? kɑɑ prəɳ kraat praanaɳ lɨɨ kɑɳkaep nɑɑ hiiɳ yum
kiiɳkoˇə? kɑɑ prəɳ kraat praanaɳ trɔɔhəɳ rumpoˇəɳ knoɳ srae praɳ
?aa khlah wiə saɳ nɨw ləə khniə

២ ) ស្រី

អ្ហា អើយ អ្ហា អឺ អឹង អើយ
ភ្លៀងធ្លាក់មកផ្សិកផ្សក់បងអើយទឹកដក់ ពេញបាតស្រែ
ក្តាមគ្រោង ក្តាមស្រង៉ែ វាកំពុងតែសន្ទនា មើលនោះឯខ្ទៅខ្សៀង
ដូចអូននិងបងនៅជិតគ្នា មើលនោះឯខ្ទៅខ្សៀង
ដូចអូននិងបងនៅជិតគ្នា សារស័ព្ទសងសន្ទនា
ដល់ខែរងា យើងដកស្ទូង

?aa ?aəy  ?aa ?əə ?əəŋ ?aəy

phliəŋ thleˇə? mɔɔk phlək phlɑ?    baaŋ ?aəy tɨk dɑ? peeɲ baat srae

kdaam krooɲ kdaam sraaŋae    wiə kampuŋ tae santeˇə?niə məəl nuh

?ae khcaw khyaaŋ

douc ?oun nɨŋ baaŋ nɨw cɨt khniə    məəl nuh ?ae khcaw khyaaŋ

douc ?oun nɨŋ baaŋ nɨw cɨt khniə    saarasap saaŋ  santeˇə?niə

dɑl khae rɔŋiə yəəŋ daak stuuŋ

៣ ) ប្រុស

អ៊្កាអើយ  អ៊្កាអឺ អឺង អើយ    សំណាបបងណ៎ាបីប្អូន

វែងដាក់ឱ្យអូនសើមថ្មីៗ    បងនិងអូនប្រវ៉ាស់ដៃ

យើងជួយគ្នាម្នាក់ម្តង

ស្ទូងស្រែអូន រួចហើយ    សូមជួយស្ទូងស្រែបង វិញផង

ស្ទូងស្រែអូន រួចហើយ    សូមជួយស្ទូងស្រែបង វិញផង

យើងជួយគ្នាម្នាក់ម្តង    ស្រែកច្រៀងផ្តោះផ្តង បងនិងស្រី

?aa ?aəy  ?aa ?əə ?əəŋ ?aəy    samnaap baaŋ naa bəy pluən wɛɛŋ

da? ?aoy ?oun saəm thməy thməy   baaŋ  nɨŋ praawah day

yəəŋ cuəy khniə mneˇə? mdaaŋ

stuuŋ srae ?oun ruəc haəy soum  cuəy  stuuŋ srae baaɲ wɨɲ phaaɲ

stuuŋ srae ?oun ruəc haəy soum  cuəy  stuuŋ srae baaɲ wɨɲ phaaɲ

yəəŋ cuəy khniə mneˇə? mdaaŋ   sraek criəŋ phdah phdaaŋ baaŋ nɨŋ srəy

៤ ) ស្រី

អ្ហ៎ា អើយ អ្ហ៎ា អឺ អឺង អើយ បងពាក់មួកស្លឹកត្នោត

ឯអូនប្រឹងជូត ក្បាលក្រម៉ា ស្ទូងរួចស្រែអូនកាលណា

អូនឥតនៅបង្អង់អី អូននឹងទៅសង ជួយស្ទូងស្រែបងឱ្យរួចដៃ

សូមអ្នកប្រុសបងកុំភ័យ កុំអាក់អន់ចិន្តា

យើងជាអ្នកស្រែចេះជួយគ្នាជារឿងធម្មតា

យើងជាអ្នកស្រែចេះជួយគ្នាជារឿងធម្មតា

ដល់ខែផល្គុណ ឯនោះណា យើងនឹងរៀបការ ជាមួយគ្នា

ʔaa ʔaəy ʔaa ʔəə ʔəəŋ ʔaəy baaŋ peˇəʔ muək slək tnaot

ʔae ʔoun prəŋ cuut kbaal kraamaa stuuŋ ruəc srae ʔoun kaal naa

ʔoun ʔət nɨw baŋʔaŋ ʔəy ʔoun nɨŋ tɨw saaŋ cuəy stuuŋ srae baaŋ ʔaoy ruəc day

soum neˇəʔ proh baaŋ kom phɨy kom ʔaʔʔan cəndaa

yəəŋ ciə neˇəʔ srae ceh cuəy khniə rɨəŋ thoˇəmmədaa

yəəŋ ciə neˇəʔ srae ceh cuəy khniə rɨəŋ thoˇəmmədaa

dal khae phalkun ʔae nuh naa yəəŋ nɨŋ riəp kaa ciə muəy khniə

៣ ) , ៤ )

## ១១. Super Woman

១ ) ស្មើរតែមួយជីវិតអូនគិតថាបងជាប្រុសល្អគ្មានផ្ទឹម  ហើយសឹងតែមួយជីវិតដែលបង មិនមែនដូចអូនយល់  ខំលាក់កុហក់លួងខ្លួនឯង ក្រែងបងមានហេតុផល តែហេតុផលផ្តល់ឲ្យ សែនគ្រោតគ្រាតក្រៃមិនគួរនឹងស្តាប់សោះ ។

stəə tae muəy ciiwɨt ?oun kɨt thaa baaŋ ciə proh l?aa khmiən phtɨm  haəy səŋ tae muəy ciiwɨt dael baaŋ mɨn mɛɛn douc ?oun yuəl  kham leˇə? ko?ho? luəŋ  khluən ?aeŋ kraeŋ baaŋ miən haet phal tae haet phal  phdal ?aoy saen kroot kriət kray  mɨn kuə nɨŋ sdap sah

២ ) មិនបង្ខំឲ្យបងបន្ទន់ចិត្ត គ្រាន់តែសុំឲ្យបងមេត្តា  មើលឃើញផងក្តីស្នេហាដែលទ្រាំលះបង់ ដោយស្ម័គ្រស្មោះ  បំពេញតាមមិនត្រូវ តម្រូវមិនអស់ គ្មានសោះអាសូរអូន  ឱបទុក្ខវេទនាគ្រាំ គ្រាបេះដូង ទើបភ្ញាក់ខ្លួនភ្លឺភ្នែកច្បាស់ ។

mɨn baŋkham ?aoy baaŋ bantuˇən cət kroˇən tae som ?aoy baaŋ meettaa  məəl khəəɲ phaaŋ  kdəy snaehaa dael troˇəm leˇə? baŋ daoy smak smah  bampeiɲ taam mɨn trəw tamrəw mɨn ?ah kmiən sah ?aasou ?oun ?aap tuk weeteˇəniə kroˇəm kriə beh douŋ təəp phŋeˇə? khluən phlɨɨ phnɛɛk cbah

៣ ) (បន្ទរ )  I'm not your super woman អូនគ្មានថាមពលក្នុងចិត្ត មិនអាចនឹងឃាត់ស្នេហ៍ ប៉ុន្តែអាចឃាត់ទឹកភ្នែកខ្លួនឯង មិនឲ្យស្រក់ មិនឲ្យធ្លាយបែក   ខ្យល់បក់នាំយកបង បងទៅទាំង មិនស្តាយ កាយឆោមឆាយចេញពីអូនចង់ច្រៀកពុះចែកគ្រប់យ៉ាង ។

?am nat yuə suupəə wuuman  ?oun khmiən thama?puˇəl knoŋ cət mɨn ?aac nɨŋ khoˇət snae pontae ?aac  khoˇət tɨk phnaek khluən ?aeŋ mɨn ?aoy sra? mɨn ?aoy  thliəy baek khyal ba? noˇəm yɔɔk baaŋ  baaŋ tɨw teˇəŋ   mɨn sdaay  kaay chaom chaay ceiɲ pii ?oun caŋ criək puh caek krup yaaŋ

៤ ) អូនគ្មានអំណាចនឹងអាចប្រាប់ព្រះអាទិត្យឲ្យប្តូរមករះនៅទិសខាងលិច ហើយក៏គ្មានសិទ្ធិនឹងផ្កាប់បញ្ជារឲ្យបងមកស្នេហ៍អូនដូចដើម តែចិត្តតិចតួចនេះចេះតែរំឭកនៅតែចាំគ្រាចាប់ផ្តើម នៅសល់ដង្ហើមនៅសល់ស្រមោលខ្មៅដៅជិតដាមស្នាមបេះដូង ។

?oun khmiən ?amnaac nɨŋ ?aac prap preˇəh ?aatɨt ?aoy pdou mɔɔk reˇəh nɨw tɨh khaaŋ lɨc haəy kaa khmiən sət nɨŋ phkoˇəp baɲciə ?aoy baaŋ mɔɔk snae ?oun douc daəm tae cət təc tuəc nih ceh tae rumlɨk nɨw tae cam kriə cap phdaəm nɨw sal daŋhaəm nɨw sal sraamaol khmaw daw dət daam snaam beh douŋ

៥ ) មិនអាចបន្តដដែកដើម្បីចាញ់ព្រោះបងបានប្តូរទៅហើយ ទឹកមាត់សាបសម្តីគ្មានន័យឡើយអស់ហើយសល់សំបកខ្លួន ផ្កាប់មិនដែលចេះត្រូវទាស់ទាំងអស់បងគ្មានសោះអាសូរអូនឱបទុក្ខវេទនាគ្រាំគ្រាបេះដូងទើបភ្ញាក់ខ្លួនភ្លឺភ្នែកច្បាស់ ។

mɨn ?aac bantaa cɔɔcɛɛk daəmbəy caɲ pruˇəh baaŋ baan pdou tɨw haəy tɨk moˇət saap samdəy khmiən nɨy laəy ?ah haəy sal sambaak khuən phkoˇəp mɨn dael ceh trəw toˇəh tiəŋ ?ah baaŋ khmiən sah ?aasou ?oun ?aop tuk weeteˇə?niə kroˇəmkriə beh douŋ təəp phŋeˇə? khluen phlɨɨ phlɛɛk cbah

៣ )

៦ ) គ្មានទេភាពយុត្តិធម៌សម្រាប់អ្នកស្មោះ គឺអូនតែម្នាក់បានលះបង់លះបង់ពេលវេលា នៅមិនអាចធ្វើជា super woman មានឈ្មោះត្រឹមមនុស្សអតិត ពាក្យពេចន៍ពីរោះប្រែផ្លាស់ន័យក្បត់ចិត្ត ចង់សួរបងថាទុកអូនដោយអ្វី ។

khmiən tee phiəp yu?te?thaan samrap neˇə? smah kɨɨ ?oun tae mneˇə? baan leˇə?baŋ leˇə?baŋ peel weeliə nɨw mɨn ?aac thwəə ciə suupəəwuuman miən chmuəh trɨm mnuh ?adət peˇə? pəc piiruəh prea phlah nɨy kbat cət caŋ suə baaŋ thaa tuk ?oun daoy ?wəy

៣ )

៧ ) ភាពអំណាត់គ្មានអំណាចគ្មានសំឡេងនឹងហៅបង ឈឺ ឈឺ លាក់ក្នុងទ្រូងចេញមក ផ្ដោះផ្ដងទទួលបេះដូងខ្ទេចខ្ទី មិនអាចឃាត់ចិត្តគេ ត្រឹមតម្រង់ចិត្តខ្លួនឯង អស់ភារៈត្រូវចំបែងបណ្ដោយ ផ្សែងឲ្យហោះហើរ តាមចិត្តចុះ ហូ ហេ យេ ខ្យល់កួចយកបង បងមិនស្ដាយដឹងហើយ

phiəp ?ɑmnɑt khmiən ?ɑmnaac khmiən sɑmleeɳ nɨɳ haw bɑɑɳ chɨɨ chɨɨ leˇə? knoɳ truɳ ceiɲ mɔɔk phdɑh phdɑɑɳ tɔtuəl beh douɳ khtec khtii mɨn ?aac khoˇət cət kee trəm tɑmrɑɳ cət khluən ?aeɳ ?ɑh phiəreˇə? trəw cɑmbaeɳ bɑndaoy phsaeɳ ?aoy hɑh haə taam cət coh huu... hei... yee... khyɑl kouc yɔɔk bɑɑɳ bɑɑɳ mɨn sdaay dəɳ haəy

៣ )

# ១២. គ្មាន ផ្លូវ khmiən phləw

១ ) មេឃគង់មានភ្លៀង ភ្លៀងគង់មានថ្ងៃរាំង បើស្នេហាត្រូវជាប់គាំង ឃាំងយកទាំងចិត្តនេះគឺគ្មានផ្លូវ យប់ក៏គង់មានថ្ងៃ ថ្ងៃប្រែតាមរដូវ តែបើឲ្យបំភ្លេចពៅ វារឹតតែគ្មានផ្លូវ បំភ្លេចថ្លៃ

meek koˇəŋ miən phliəŋ phliəŋ koˇəŋ miən thŋay riəŋ baə snae haa trəw coˇəp kiəŋ khiəŋ yɔɔk teˇəŋ cət nih kɨɨ khmiən phləw yup kaa koˇəŋ miən thŋay thŋay prae taam rɔdəw tae baə ?aoy bamphlec pɨw wiə rɨt tae khmiən phləw bamphlec thlay

២ ) ទឹកភ្នែកលួចពូនជ្រុំយំក្នុងបេះដូង ស្ងួតទាំងខ្លួនខ្សោះរីងរៃ តែនៅគ្មានផ្លូវកែចិត្តបង្ខិតលុបស្នេហ៍ចាស់ ប្រឹងញញឹមបន្លប់ក្រែងលើកលែង ប្រាប់ខ្លួនឯងគ្មានឱកាស តែចិត្តរីងរូសបេះដូងមានះប្រាកដមិនអាចប្តូរផ្លាស់ព្រោះនៅស្នេហ៍ដូចដើម ស្នេហ៍គ្មានផ្លូវកែចិត្ត ។ (ភ្លេង)

tɨk phnɛɛk luəc puun crum yum knoŋ beh douŋ sŋuut teˇəŋ khluən khsah riiŋrɨy tae nɨw khmiən phləw kae cət baŋkhət lup snae cah prəŋ ɲɔɲɨm banlap kraeŋ ləək laeŋ prap khluən ?aeŋ khmiən ?oukaah tae cət rɨŋruuh beh douŋ miəneˇə praakat mɨn ?aac pdou phlaah pruˇəh nɨw snae douc daəm snae khmiən phləw kae cət

៣ ) ស្នាមលើក្រដាស គង់មានថ្ងៃរលុប ល្ខោនគង់មានថ្ងៃចប់ តែបើឲ្យចប់ចិត្តនេះគឺគ្មានផ្លូវ ពណ៌គង់មានពេលប្រែ ស្នេហ៍ដែលបងបានដៅ ធ្លាក់ទុកក្នុងបេះដូងពៅ ត្រូវបិទឈប់នឹកនាទៀតមិនបាន ។

snaam ləə kraadaah koˇəŋ miən thŋay rɔlup lkhaon koˇəŋ miən thŋay cap tae baə ?aoy cap cət nih kɨɨ khmiən phləw puə koˇəŋ miən peel prae snae dael baaŋ baan daw trəw bət chup nɨk niə tiət mɨn baan

២ )

៤) បងនៅចាំត្រង់នេះនៅត្រង់នេះ ដឹងទេថ្ងៃមិនធ្លាប់ប្រែចិត្តពីថ្ងៃប្រែពីស្រីប្រែពីស្រី ស្នេហ៍គ្មានផ្លូវកែចិត្ត ។

baaɳ nɨw cam trɑɳ nih nɨw trɑɳ nih dəɳ tee thlay mɨn thloˇəp prae cət pii thlay prae pii srəy prae pii srəy snae khmiən phləw kae cət

## ១៣. នគររាជ nɔkɔɔ riəc

១. សូមពួកទេវតា រក្សាមហាក្សត្រយើង
អោយបានរុងរឿង ដោយជ័យមង្គលសិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី វង្សក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន។

soum puək teeweˇədaa reˇə?saa mɔhaa ksat yəəɳ
?aoy baan ruɳ rɨəɳ daoy cɨy muˇəɳkuˇəɳ serəy suəsdəy
yəəɳ khɲom preˇə?ɑɳ soum crɔɔk kraom mlup preˇə baareˇəməy
nɨy preˇə neˇəreˇəpdəy woˇəɳ ksatraa dael saaɳ praasaat thmɑɑ
krup krɔɔɳ daen khmae bo?raan thkaəɳ thkaan

២. ប្រាសាទសីលា កំបាំងកណ្ដាលព្រៃ
គួរអោយស្រមៃ នឹកដល់យសស័ក្តិមហា
ជាតិខ្មែរដូចថ្មគង់វង្សនៅល្អរឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ។

praasaat səylaa kɑmbaɳ kɑndaal prɨy
kuə ?aoy sraɑmay nɨk dɑl yuˇəh sak mɔɔha
ciət khmae douc thmɑɑ koˇəɳ woˇəɳ nɨw l?ɑɑ rɨɳ pəɳ cumhɔɔ
yəəɳ saɳkɨm pɔɔ phoˇəp preeɳ sɑmnaaɳ rɔbaah kɑmpuciə
mɔhaa ruˇət kaət miən yuu ?ɑɳwɛɛɳ haəy

៣. គ្រប់វត្តអារាម ឮតែសូរស័ព្ទធម៌

សូត្រដោយអំណរ រំឭកគុណពុទ្ធសាសនា

ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា

គង់តែទេវត្តានឹងជួយជ្រោមជ្រែង ផ្គត់ផ្គង់ប្រយោជន៍ឱយ

ដល់ប្រទេសខ្មែរ ជាមហានគរ។

krup woˇət ?aaraam lɨɨ tae sou sap thɑɑ

sout daoy ?ɑmnɑɑ rumlɨk kun put saahsnaa

cou yəəŋ ciə neˇə? cɨə ceˇə? smɑh smak taam baep doun taa

koˇəŋ tae teeweˇədaa nɨŋ cuəy croomcrɛɛŋ phkuˇət phkuˇəŋ prɑɑyɑɑc ?aoy

dɑl prɑɑteeh khmae ciə mɔhaa nɔkɔɔ

ɑəɨɳɔeˇəuˇəoˇəɛ